គោលលទ្ធិ និង សេចក្ដីសញ្ញា
១០២–១០៥

# ជំរំស៊ីយ៉ូន—ការរៀបចំខ្លួនដើម្បីបម្រើព្រះអម្ចាស់

ក្រោយពីក្រុមសមាជិកនៃសាសនាចក្រត្រូវបានស្គាល់ថាជំរំ ស៊ីយ៉ូន បានដើរក្បួនរាប់រយគីឡូម៉ែត្រដើម្បីជួយដល់សមាជិកពួកបរិសុទ្ធថ្ងៃចុងក្រោយរបស់ពួកគេ នោះព្រះអម្ចាស់បានប្រាប់ យ៉ូសែប ស្ម៊ីធ ឲ្យរំសាយក្រុម ទោះបីពួកគេគិតថា ពួកគេមិនបានសម្រេចគោលដៅរបស់ពួកគេក៏ដោយ ។ ដោយសារតែហេតុផលនេះហើយ មានមនុស្សខ្លះបានហៅជំរំស៊ីយ៉ូនថាពួកបរាជ័យ ប៉ុន្តែអស់អ្នកដែលបានចូលរួមបានថ្លែងទីបន្ទាល់ថា បទពិសោធន៍របស់ពួកគេបានរៀបចំពួកគេសម្រាប់ការបម្រើព្រះអម្ចាស់នៅពេលអនាគត ។

នៅអំឡុងពេលនៃការហែក្បួនដ៏វែងនេះសមាជិកជំរំខ្លះបានត្អូញត្អែរ និងបាននិយាយប្រឆាំងនឹងព្យាការីយ៉ូសែប ប៉ុន្តែអ្នកផ្សេងទៀតស្មោះត្រង់នឹងលោក ហើយបានរៀនពីការអត់ធ្មត់ និងការគោរពប្រតិបត្តិ ។




### ការពិភាក្សា

តើបងប្អូនគិតថាវាមានន័យយ៉ាងណាដើម្បីប្រោសលោះស៊ីយ៉ូន ? ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ១០៣:១៥ ) ។